## ការចាក់វ៉ាក់សាំង Covid-19
## ដឹងអំពីសិទ្ធិរបស់អ្នកក្នុងនាមជាសមាជិកសហគមន៍ជនអន្តោប្រវេសន៍

- វ៉ាក់សាំងនេះអាចទទួលបានដោយឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នានៅសហរដ្ឋអាមេរិកដោយមិនគិតពីស្ថានភាពសញ្ជាតិ (ទោះបីជាអ្នកគ្មានឯកសារបញ្ជាក់ក៏ដោយ)។ បំណ្ណធានារ៉ាប់រងអាចត្រូវបានស្នើសុំឲ្យមាន ប៉ុន្តែមិនតម្រូវឲ្យប្រើដើម្បីទទួលបានវ៉ាក់សាំងទេ។

- social security number (លេខសន្តិសុខសង្គម) មិនតម្រូវឲ្យប្រើដើម្បីទទួលបានវ៉ាក់សាំងទេ។ ប្រសិនបើអ្នកផ្តល់សេវាសួរអ្នករក social security number ហើយអ្នកមិនមាន ឬមិនមានអារម្មណ៍សុខស្រួលក្នុងការចែករំលែកវា អ្នកអាចឆ្លើយតបថាអ្នកមិនមាន ឬមិនមានអារម្មណ៍សុខស្រួលក្នុងការចែករំលែកវា។

- អ្នកអាចនឹងត្រូវបានស្នើសុំឲ្យមានការបញ្ជាក់អត្តសញ្ញាណបំណ្ណដើម្បីទទួលបានវ៉ាក់សាំងរបស់អ្នក។ ប្រសិនបើអ្នកមិនមានបំណ្ណសម្គាល់របស់រដ្ឋ/បំណ្ណបើកបរ អ្នកអាចត្រូវបានស្នើសុំឲ្យផ្តល់លិខិត ការបញ្ជាក់ ឬវិក្កយបត្រសេវាសាធារណៈដែលមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក ឬលិខិតពីព្រះវិហារ អង្គការ ឬអ្នកផ្តល់សេវាដែលស្គាល់អ្នកដើម្បីអះអាងថាអ្នករស់នៅ ឬធ្វើការនៅរដ្ឋវ៉ាស៊ីនតោន។

- Centers for Disease Control and Prevention (មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ)និងDepartment of Health and Human Services (នាយកដ្ឋានសុខាភិបាល និងសេវាកម្មមនុស្ស) បានសង្កត់ធ្ងន់ថាទិន្នន័យផ្ទាល់ខ្លួននឹងត្រូវប្រើប្រាស់សម្រាប់គោលបំណងសុខភាពសាធារណៈតែប៉ុណ្ណោះ។ ទិន្នន័យផ្ទាល់ខ្លួនអាចនឹងមិនត្រូវបានប្រើសម្រាប់ការកាត់ទោសរដ្ឋប្បវេណី ឬព្រហ្មទណ្ឌរួមទាំងការអនុវត្តច្បាប់អន្តោប្រវេសន៍ឡើយ។

- ការទទួលយកវ៉ាក់សាំងមិនរាប់បញ្ចូលជាការគិតថ្លៃសាធារណៈទេ។ ការប្រើប្រាស់វ៉ាក់សាំងនឹងមិនរារាំងឱកាសណាមួយក្នុងការទទួលបានស្ថានភាពស្នាក់នៅនិង/ឬសញ្ជាតិឡើយ។

- គ្មាននរណាម្នាក់គួរសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកដើម្បីទទួលបានវ៉ាក់សាំងទេ ប៉ុន្តែប្រសិនបើអ្នកត្រូវបានគេសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកនៅពេលណាមួយ អ្នកមានសិទ្ធិមិនឆ្លើយតបបាន។

- អ្នករាល់គ្នាអាចចាក់វ៉ាក់សាំងបានដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ អ្នកមិនចាំបាច់ផ្តល់ឯកសារភស្តុតាងបញ្ជាក់ស្ថានភាពអន្តោប្រវេសន៍របស់អ្នក ដើម្បីទទួលបានវ៉ាក់សាំងឡើយ។

សូមថ្លែងអំណរគុណជាពិសេសចំពោះLegal Counsel for Youth and Children (LCYC, មេធាវីតំណាងយុវជន និងកុមារ) និង Northwest Health Law Advocates (NoHLA, អ្នកតស៊ូមតិច្បាប់សុខាភិបាលតំបន់ពាយព្យ)
ឯកសារនេះត្រូវបានត្រួតពិនិត្យដោយDOH (ក្រសួងសុខាភិបាល)រដ្ឋវ៉ាស៊ីនតោន

Washington State Department of Health

WASHINGTON IMMIGRANT SOLIDARITY NETWORK